ថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០១១

# សេចក្តីប្រកាសព័ត៌មាន

## ស្តីពី

## លទ្ធផលការអង្កេត និងការវាយតម្លៃលើការអនុវត្តកម្មវិធីនយោបាយដែលមានសូចនាករច្បាស់លាស់របស់រាជរដ្ឋាភិបាល និងមន្ត្រីជាប់ឆ្នោតនីតិកាលទី៤ (របាយការណ៍ប្រចាំឆ្នាំ ២០០៩-២០១០)

គណៈកម្មាធិការខុមហ្វ្រែនៅថ្ងៃនេះ បានចេញផ្សាយរបាយការណ៍លទ្ធផលការអង្កេត និងការវាយតម្លៃលើការអនុវត្តកម្មវិធីនយោបាយដែលមានសូចនាករច្បាស់លាស់របស់រាជរដ្ឋាភិបាល និងមន្ត្រីជាប់ឆ្នោតនីតិកាលទី៤ (របាយការណ៍ប្រចាំឆ្នាំ ២០០៩-២០១០)។

លោក គល់ បញ្ញា នាយកប្រតិបត្តិខុមហ្វ្រែល មានប្រសាសន៍ថា "របាយការណ៍នឹងលើកទឹកចិត្តឲ្យម្ចាស់ឆ្នោតឃ្លាំមើល និងវាយតម្លៃការអនុវត្តការសន្យារបស់មន្ត្រីជាប់ឆ្នោត។ របាយការណ៍ក៏ផ្តល់ព័ត៌មានត្រឡប់ និងមតិរបស់ម្ចាស់ឆ្នោតទៅរាជរដ្ឋាភិបាល និងមន្ត្រីជាប់ឆ្នោត។

ទាក់ទិនការអង្កេត គណៈកម្មាធិការខុមហ្វ្រែលបានសិក្សាទៅលើកម្មវិធីនយោបាយរាជរដ្ឋាភិបាលនីតិកាលទី៤ ដែលការសន្យាមានសូចនាករច្បាស់លាស់ចំនួន១០។

របាយការណ៍អង្កេតរកឃើញថា រាជរដ្ឋាភិបាលបានសំរេចការសន្យារបស់ខ្លួនទាំងស្រុងតែ៣ (៣០%) ប៉ុណ្ណោះ គិតមកត្រឹមចុងឆ្នាំ២០១០នេះដូចជា ការដំឡើងប្រាក់បៀវត្សរ៍ជូនមន្ត្រីរាជការ និងកងកំលាំងប្រដាប់អាវុធយ៉ាងតិច ២០%ក្នុងមួយឆ្នាំ ការបង្កើនផ្ទៃដីដោះមីនរួចឲ្យដល់ ៤៥,000 ហិកតានៅឆ្នាំ ២០១០ និងការផ្គត់ផ្គង់ទឹកស្អាតដល់ប្រជាជននៅជនបទបានប្រមាណ៤0% នៅក្នុងឆ្នាំ២០១០។

៧0% នៃការសន្យាដែលមានសូចនាករច្បាស់លាស់ មិនត្រូវបានបំពេញទាំងស្រុងមានដូចជា ការរក្សាកំណើនសេដ្ឋកិច្ចប្រចាំឆ្នាំជាមធ្យម ៧% ការរក្សាកំណើនភ្ញៀវទេសចរបរទេសឲ្យបាន២0%ជារៀងរាល់ឆ្នាំ ការរៀបចំបង្កើតប្រព័ន្ធសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការ កងកំលាំងប្រដាប់អាវុធ កម្មករ និយោជិត ។ល។

ចំណែកការវាយតម្លៃលើកម្មវិធីនយោបាយដែលមិនមានសូចនាករច្បាស់លាស់ ខុមហ្វ្រែលបានយកទៅពិភាក្សាជាមួយប្រជាពលរដ្ឋទាំង២៤មណ្ឌល (រាជធានី/ខេត្ត) ដើម្បីកំណត់លក្ខខណ្ឌសន្ទស្សន៍ (សូចនាករ) ដែលចង្អុលបង្ហាញដោយយុទ្ធសាស្រ្តចតុកោណដំណាក់កាលទី២។ នៅឆ្នាំ២០១០ ខុមហ្វ្រែលបានយកលក្ខណ្ឌសន្ទស្សន៍ទាំងនេះត្រឡប់ទៅឲ្យប្រជាពលរដ្ឋនៅតាមមណ្ឌលខេត្តនៅតាមមណ្ឌល កំពង់ស្ពឺ កំពង់ឆ្នាំង កំពត រតនៈគីរី សៀមរាប ឧត្តរមានជ័យ ព្រៃវែង និងប៉ៃលិន (៨ មណ្ឌល) ដើម្បីផ្តល់ពិន្ទុលើការបំពេញរបស់

Vision : A democratic society that democratization in particular democratic elections are promoted and qualified to bring benefits to people.

ទីស្នាក់ការកណ្តាល ៖ ផ្ទះលេខ ១៣៨ ផ្លូវ ១២២ សង្កាត់ ទឹកល្អក់ ១ ខណ្ឌ ទួលគោក រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
**Central Office** : #138, Street. 122, Teuk Laak I, Tuol Kork, Phnom Penh, CAMBODIA.
**P.O. Box** 1145, **Phone** : (855) 23 884 150 **Fax**: (855) 23 885 745 **E-mail** : comfrel@online.com.kh **Website**: www.comfrel.org

មន្ត្រីរាជរដ្ឋាភិបាល និងមន្ត្រីជាប់ឆ្នោត។ ជាលទ្ធផល វេទិកាចំនួន៨ដែលឲ្យម្ចាស់ឆ្នោតផ្តល់ពិន្ទុ (សរុបមាន ៨០សន្ទស្សន៍៖ (១០ សន្ទស្សន៍នៃមណ្ឌលនីមួយ x ៨ មណ្ឌល)។

បើគិតជាមធ្យមវិញ មានតែ២.៥% (ស្មើនឹង២សន្ទស្សន៍/ចំនុច) នៃសន្ទស្សន៍ទាំងអស់ ដែលត្រូវបានម្ចាស់ឆ្នោតភាគច្រើនវាយតម្លៃថា បានសម្រេច ឬបំពេញបានភាគច្រើន ឬស្ទើរតែទាំងស្រុង។ ១.២៥% (ស្មើនឹង១សន្ទស្សន៍/ចំនុច) នៃសន្ទស្សន៍ទាំងអស់ត្រូវបានម្ចាស់ឆ្នោតវាយតម្លៃថា បានធ្វើច្រើន។

១៨.៧៥% (ស្មើនឹង ១៥សន្ទស្សន៍/ចំនុច) នៃសន្ទស្សន៍ទាំងអស់ត្រូវបានម្ចាស់ឆ្នោតភាគច្រើនវាយតម្លៃថា បានធ្វើមធ្យម ឬបានធ្វើពាក់កណ្តាល។

៧៧.៥% (ស្មើនឹង ៦២សន្ទស្សន៍) នៃសន្ទស្សន៍ទាំងអស់ត្រូវបានម្ចាស់ឆ្នោតភាគច្រើនវាយតម្លៃថា បានធ្វើខ្លះ (៤២.៥%) និងមិនបានធ្វើទាល់តែសោះ ឬបានធ្វើតិចតួច (៣៥%)។

ជាសរុប នេះគឺជាសញ្ញាវិជ្ជមានដែលរាជរដ្ឋាភិបាលបានបំពេញសន្ទស្សន៍ច្បាស់លាស់នៃកម្មវិធីនយោបាយ ខណៈដែលរាជរដ្ឋាភិបាលនៅមានរយៈពេល ៣ឆ្នាំបន្តទៀត។ ប៉ុន្តែ ម្ចាស់ឆ្នោតនៅតាមមណ្ឌលមិនទាន់ពេញចិត្តការបំពេញរបស់រាជរដ្ឋាភិបាលចំពោះការកែលំអរ គោលនយោបាយលើបញ្ហាដីធ្លី តម្លៃសេវាព្យាបាល (ពេទ្យ) តម្លៃអគ្គីសនី កំណែទម្រង់ប្រព័ន្ធយុត្តិធម៌ និងរដ្ឋបាលសាធារណៈ។

របាយការណ៍ពិស្តារនៃលទ្ធផលអង្កេតនេះ អាចរកបាននៅគេហទំព័រខុមហ្វ្រែល៖www.comfrel.org ។

***<u>សម្រាប់ព័ត៌មានបន្ថែម, សូមទំនាក់ទំនង៖</u>***

លោក **សុខ ពិទូរ្យ** អ្នកសម្របសម្រួលផ្នែកអង្កេតខុមហ្វ្រែល

ទូរស័ព្ទ៖ ០៨៩ ៥២៥ ៤៤៦ អ៊ីម៉ែល៖ pitour@comfrel.org

<u>បេសកកម្ម</u> ៖ បេសកកម្មរបស់ខុមហ្វ្រែល គឺជួយបង្កើតបរិយាកាសគួរជាទីពេញចិត្ត និងមានព័ត៌មានគ្រប់គ្រាន់ ទី១/**ដើម្បីឱ្យមានដំណើរការបោះឆ្នោតដោយសេរី និងយុត្តិធម៌** តាមរយៈការបញ្ចុះបញ្ចូល តស៊ូមតិ ដើម្បីទទួលបាននូវក្របខ័ណ្ឌច្បាប់សមរម្យ, ការអប់រំដើម្បីផ្តល់ព័ត៌មានដល់អ្នកបោះឆ្នោត អំពីសិទ្ធិ និងសកម្មភាពចូលរួមសង្កេតការណ៍របស់ពួកគេ ដែលអាចរារាំងនូវភាពមិនប្រក្រតី ព្រមទាំងផ្តល់នូវរបាយការណ៍អង្កេតយ៉ាងទូលំទូលាយ និងឆាប់រហ័ស ដើម្បីអាចឲ្យមានការវាយតម្លៃលើដំណើរការ បោះឆ្នោតមួយដែលមិនលំអៀង និងមិនប្រកាន់បក្សពួក ទី២/ **ដើម្បីឱ្យមានអត្ថន័យនៃដំណាក់កាលក្រោយពេលបោះឆ្នោត** តាមរយៈការអប់រំ និងវេទិកាសាធារណៈក្នុងគោលបំណងជំរុញលើកទឹកចិត្តប្រជាពលរដ្ឋឱ្យចូលរួមក្នុងកិច្ចការនយោបាយ និងការធ្វើសេចក្តីសំរេចនានា ការតស៊ូមតិ/បញ្ចុះបញ្ចូលដើម្បីឱ្យមានការកែទម្រង់ ដំណើរការបោះឆ្នោតដែលបង្កើននូវគណនេយ្យភាព (ការទទួលខុសត្រូវ) របស់មន្ត្រីជាប់ឆ្នោត ព្រមទាំងផ្តល់នូវរបាយការណ៍អង្កេតយ៉ាងទូលំទូលាយ និងឆាប់រហ័ស ដើម្បីអាចឱ្យមានការវាយតម្លៃមួយដែលមិនលំអៀង និងប្រកាន់បក្សពួក ទៅលើការបំពេញកម្មវិធីនយោបាយ និងដំណើរការអនុវត្តន៍ ការងាររបស់មន្ត្រីជាប់ឆ្នោត។